





# សៀវភៅណែនាំអំពី
# សេវាអន្តរាគមន៍បឋមវ័យរបស់គ្រួសារក្នុងរដ្ឋ Washington

*Individuals with Disabilities Education Act (ច្បាប់អប់រំបុគ្គលដែលមានពិការភាព, IDEA)*







Washington State Department of
CHILDREN, YOUTH & FAMILIES



នៅពេលដែលលោកអ្នកចាប់ផ្តើមដឹងថា កូនរបស់លោកអ្នកមានការយឺតយ៉ាវផ្នែកអភិវឌ្ឍន៍សម្បទា, នោះលោកអ្នកនឹងមានអារម្មណ៍ច្របូកច្របល់មិនដាច់ស្រេចជាច្រើនអន្លើ។ លោកអ្នកអាចនឹងមានអារម្មណ៍ភ័យខ្លាច, លោកអ្នកអាចនឹងមិនជឿនូវអ្វីដែលលោកអ្នកឮគេឯងនិយាយ ឬលោកអ្នកអាចនឹងមានអារម្មណ៍ម៉ូម៉ៅពីនេះពីនោះផង ក៏សឹងមាន។ ទាំងនេះមិនមែនជាអារម្មណ៍ខុសប្លែកពីធម្មតាទេ ហើយលោកអ្នកក៏មិនមែនមានអារម្មណ៍បែបនេះតែម្នាក់ឯងដែរ។ ឪពុកម្តាយដទៃៗទៀតក៏មានអារម្មណ៍ដូច្នេះដែរ។ មានកម្មវិធីជាច្រើននៅពាសពេញទូទាំងរដ្ឋ ដែលអាចជួយភ្ជាប់លោកអ្នកទៅនឹងឪពុកម្តាយដទៃៗទៀតដែលមានអារម្មណ៍ ឬទុក្ខកង្វល់ដូចជាលោកអ្នកនេះដែរ។ លោកអ្នកអាចទូរស័ព្ទទាក់ទងទៅបណ្តាសមាជិកគាំពារមាតាបិតា តាមលេខទូរស័ព្ទដែលបានចុះនៅលើទំព័រខាងក្រោយនៃកូនសៀវភៅនេះ ដើម្បីស្វែងយល់ពត៌មានពិស្តារបន្ថែម ព្រមទាំងស្វែងរកជំនួយផ្សេងៗ។

## ជូនចំពោះមាតាបិតាទាំងឡាយជាទីគោរពរាប់អាន,

*ប្រសិនបើលោកអ្នកមានកូនសៀវភៅនេះ, នោះខ្ញុំដឹងថា លោកអ្នកប្រហែលជាកំពុងមានកង្វល់អំពីការអភិវឌ្ឍន៍កាយសម្បទារបស់កូនលោកអ្នក ឬលោកអ្នកប្រហែលជាកំពុងឮគេប្រាប់ថា កូនរបស់លោកអ្នកមានការយឺតយ៉ាវផ្នែកអភិវឌ្ឍន៍កាយសម្បទា។*

*ខ្ញុំនៅចាំមិនភ្លេចទេ អំពីអារម្មណ៍ច្របូកច្របល់ និងវង្វេងវង្វាន់ដែលខ្ញុំមាន ក្នុងកាលដែលកូនស្រីរបស់ខ្ញុំ, នាង (Suzi), បានត្រូវគេធ្វើតេស្តពិនិត្យមើលអាការយឺតយ៉ាវខាងផ្នែកអភិវឌ្ឍន៍កាយសម្បទារបស់នាង។ នៅពេលនោះ ខ្ញុំស្តាប់មិនយល់ពាក្យជាច្រើន ដែលអ្នកឯកទេសគេបានប្រាប់ខ្ញុំ, តែខ្ញុំបានទុកការបារម្ភនោះមួយអន្លើ ហើយបែរទៅរកសេវាកម្ម។*

*នៅពេលយើងបានទទួលសេវាកម្មដែលយើងត្រូវការទាំងប៉ុន្មានហើយ, តាមរយៈគ្រូបង្រៀន និងគ្រូព្យាបាលរោគប៉ិនប្រសប់ជាច្រើនរូប, នោះអាការយឺតយ៉ាវរបស់នាងក៏បានវិវឌ្ឍន៍ប្រសើរឡើងបន្តិចម្តងៗ។ គុណបំណាច់ដ៏ធំដែលនាំឲ្យនាងមានថ្ងៃនេះ គឺសេវាអន្តរាគមន៍បឋមវ័យដែលជាយន្តការនាំនាងឆ្លងកាត់ថ្ងៃខែឆ្នាំដ៏គ្រោតគ្រាតទាំងអម្បាលម៉ាន ក្នុងវ័យបឋមរបស់នាង។ ការប្រាស្រ័យទាក់ទងជាមួយឪពុកម្តាយដទៃៗទៀត និងការចែករំលែកពត៌មានគ្នាទៅវិញទៅមក ក៏ជាការសំខាន់បំផុតមួយទៀតសម្រាប់គ្រួសារយើងដែរ។*

*ខ្ញុំសង្ឃឹមថា លោកអ្នកនឹងប្រើកូនសៀវភៅដ៏មានតម្លៃមួយនេះ ទុកជាសេចក្តីណែនាំ ដើម្បីរុករកសេវាកម្ម និងការឧបត្ថម្ភគាំពារនានា ដែលគ្រួសាររបស់លោកអ្នកត្រូវការ។*

**Cassie, មាតាមួយរូប**

# មាតិកា


សេចក្តីផ្តើម . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . 2

តើអន្តរាគមន៍បឋមវ័យជាអ្វី? . . . . . . . . . . . . . . . . . . . . . . . . . . . . 3

ចុះបើខ្ញុំមានសំណួរស្តីអំពីការអភិវឌ្ឍន៍កាយសម្បទារបស់កូនខ្ញុំ? . . . 4

តើនរណាជាអ្នកមានលក្ខណសម្បត្តិទទួលសេវាអន្តរាគមន៍
បឋមវ័យក្នុងរដ្ឋ Washington? . . . . . . . . . . . . . . . . . . . . . . . . . . . 5

តើនឹងមានអ្វីកើតឡើងបន្ទាប់មកទៀត? . . . . . . . . . . . . . . . . . . . . . 6

តើនឹងមានអ្វីកើតឡើងនៅពេលបានអាយុ 3 ឆ្នាំ? . . . . . . . . . . . . . . . 7

តើសិទ្ធិរបស់ខ្ញុំក្រោម Individuals with Disabilities
Education Act (ច្បាប់អប់រំបុគ្គលដែលមានពិការភាព, IDEA)
មានអ្វីខ្លះ? (ការការពារសុវត្ថិភាពតាមនីតិវិធី) . . . . . . . . . . . . . . . . . . 8

ចុះបើខ្ញុំមិនយល់ស្របតាមសេចក្តីសម្រេចណាមួយ
ស្តីអំពីសេវាកម្មរបស់កូនខ្ញុំ ឬរបស់គ្រួសារខ្ញុំ? . . . . . . . . . . . . . . . . . 10

តើខ្ញុំអាចទៅរកជំនួយ ឬពត៌មានពិស្តារបន្ថែមនៅទីណា? . . . . . . . . . 11

តើខ្ញុំអាចចូលរួមឲ្យកាន់តែច្រើនថែមទៀតដោយរបៀបណា? . . . . . 12

ពាក្យនោះមានន័យដូចម្តេច? (សទ្ទានុក្រម) . . . . . . . . . . . . . . . . . . . . 13

ការទទួលស្គាល់ . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . 14




# សេចក្តីផ្តើម

*"ពេលដែលកូនប្រុសខ្ញុំបានអាយុប្រាំមួយខែ វានៅតែមិនទាន់ចេះអង្គុយ។ ខ្ញុំបានគិតថា ប្រហែលជាខ្ញុំបានធ្វើអ្វីខុសហើយ ទើបវាទៅជាយ៉ាងនេះ។ ខ្ញុំបានយកវាទៅជួបគ្រូពេទ្យរបស់យើង ដែលបានជួយបញ្ជូនខ្ញុំទៅរកជំនួយពីកម្មវិធីអន្តរាគមន៍បឋមវ័យ។ ឥឡូវនេះ កូនប្រុសរបស់ខ្ញុំកំពុងទទួលបានសេវាកម្មមួយចំនួន ដែលជួយវាយ៉ាងសម្បើម។ វាកំពុងវិវឌ្ឍន៍ប្រសើរឡើងបន្តិចម្តងៗ គួរជាទីគាប់ចិត្ត ហើយខ្ញុំក៏ខិតខំរៀនសូត្របន្ថែមទៀតអំពីអ្វីដែលខ្ញុំអាចធ្វើសម្រាប់វា។ ឥឡូវនេះ ខ្ញុំដឹងថា មិនមែនដោយសារខ្ញុំបានធ្វើអ្វីខុសនេះ ទើប Ian មិនអាចធ្វើអ្វីៗបានយ៉ាងឆាប់រហ័សដូចក្មេងដទៃៗដូច្នេះ"។*

***Heather,* មាតាមួយរូប**



**គោលបំណងចម្បងនៃសៀវភៅណែនាំនេះ** គឺដើម្បីផ្តល់ជូនលោកអ្នក និងគ្រួសាររបស់លោកអ្នកនូវសេចក្តីសង្ខេបស្តីអំពីកម្មវិធី Early Support for Infants and Toddlers (ឧបត្ថម្ភបឋមវ័យសម្រាប់ទារក និងកុមារវ័យក្មេង, ESIT) របស់ Department of Children, Youth, and Families (ក្រសួងកុមារ យុវជន និងគ្រួសារ, DCYF) រដ្ឋ Washington។ ការចូលរួមរបស់គ្រួសារលោកអ្នកក្នុងកម្មវិធី ESIT នេះ គឺជាជម្រើសស្ម័គ្រចិត្តរបស់លោកអ្នក។ ប្រសិនបើកូនរបស់លោកអ្នកត្រូវបានគេរកឃើញថា មានលក្ខណសម្បត្តិទទួលកម្មវិធី ESIT, នោះសេវាអន្តរាគមន៍បឋមវ័យមានបម្រុងសម្រាប់បម្រើការជូនកូន និងគ្រួសាររបស់លោកអ្នក ដើម្បីដោះស្រាយបញ្ហាយឺតយ៉ាវក្នុងការអភិវឌ្ឍន៍កាយសម្បទារបស់កូនលោកអ្នក។

សៀវភៅនេះផ្តល់ជូនលោកអ្នកនូវពត៌មានទូទៅ និងសំខាន់ៗស្តីអំពីកម្មវិធី ESIT ដែលមានបម្រើការពាសពេញរដ្ឋ, ដោយរួមមានទាំងការបំភ្លឺអំពីសិទ្ធិមួយចំនួនរបស់លោកអ្នក ក្នុងនាមជាមាតាបិតាផង។ សេចក្តីពណ៌នាលម្អិតទាំងស្រុងស្តីអំពីនីតិវិធីការពារ/សិទ្ធិរបស់មាតាបិតាមានបម្រុងជូនលោកអ្នក និងគ្រួសាររបស់លោក នៅក្នុងសៀវភៅដាច់ដោយឡែកមួយទៀត ដែលមានចំណងជើងថា "Individuals with Disabilities Education Act (ច្បាប់អប់រំបុគ្គលដែលមានពិការភាព, IDEA) មាត្រា Part C នីតិវិធីការពារ (សិទ្ធិរបស់មាតាបិតា)"។ ក្នុងខណ:ដែលលោកអ្នកកំពុងអានសៀវភៅណែនាំនេះ, នោះ family resources coordinator (បុគ្គលិកសម្របសម្រួលធនធានគ្រួសារ, FRC) របស់លោកអ្នក ឬបុគ្គលិកណាម្នាក់ពីកម្មវិធី ESIT អាចជួយឆ្លើយបំភ្លឺសំណួរនានា ដែលលោកអ្នកអាចនឹងមានស្តីអំពីកម្មវិធីនេះ។

ឯកសារនេះត្រូវបានសរសេរតាក់តែងឡើង ដោយប្រើពាក្យបច្ចេកទេសមួយចំនួន ពាក់ព័ន្ធសេវាអន្តរាគមន៍បឋមវ័យ។ បើលោកអ្នកមានសំណួរអំពីពាក្យទាំងនេះ ហើយត្រូវការពិនិត្យមើលនិយមន័យរបស់វា, សូមអញ្ជើញអានសទ្ទានុក្រមលើទំព័រទី 13 នៃកូនសៀវភៅនេះ។

## កម្មវិធី **Early Support for Infants and Toddlers** (ឧបត្ថម្ភបឋមវ័យសម្រាប់ទារក និងកុមារក្មេងវ័យ, **ESIT**) នៃរដ្ឋ **Washington**

ក្នុងនាមជាមាតាបិតា, លោកអ្នកគឺជាមនុស្សសំខាន់បំផុតនៅក្នុងជីវិតរបស់កូនលោកអ្នក។ នៅក្នុងរយ:កាលបីឆ្នាំដំបូងនៃជីវិតរបស់វា, កូនរបស់លោកអ្នកលូតលាស់ចម្រើនវ័យឆាប់រហ័សណាស់។ សូមលោកអ្នកយកចិត្តទុកដាក់នឹងកូន ហើយនិងវ័យលូតលាស់របស់វា។ លោកអ្នកគឺជាមនុស្សតែម្នាក់គត់ដែលស្គាល់កូនរបស់លោកអ្នកច្បាស់លាស់ជាងគេ។ សូមលោកអ្នកសម្គាល់មើល ដោយហ្មត់ចត់អំពីបែបបទផងទាំងពួង ដូចជារបៀប និងពេលវេលាដែលកូនរបស់លោកអ្នកចាប់ផ្តើមចេះញញឹម, ចេះអង្គុយ, ចេះដើរ, ចេះនិយាយ, ឬចេះកាន់កែវផឹកទឹកជាដើម។ អ្វីដែលលោកអ្នកកំពុងសម្គាល់ឃើញនេះ គឺជាការធំលូតលាស់ចម្រើនវ័យទៅតាមដំណាក់កាលនីមួយៗនៃការអភិវឌ្ឍន៍កាយសម្បទារបស់កូនលោកអ្នក។ នៅពេលណាដែលកូនមានបញ្ហាយឺតយ៉ាវក្នុងការអភិវឌ្ឍន៍កាយសម្បទា, នោះលោកអ្នកអាចស្វះស្វែងរកជំនួយ ដែលមានបម្រើការនៅពាសពេញទូទាំងរដ្ឋ។ កម្មវិធី Early Support for Infants and Toddlers (ឧបត្ថម្ភបឋមវ័យសម្រាប់ទារក និងកុមារក្មេងវ័យ, ESIT) នៃរដ្ឋ Washington ត្រូវបានបង្កើតឡើង ហើយដាក់ឲ្យដំណើរការនៅទូទាំងរដ្ឋ ដើម្បីជួយក្រុមគ្រួសារនៃពលរដ្ឋទាំងឡាយឲ្យទទួលបាននូវជំនួយទាំងនេះ នៅពេលណាពួកគេត្រូវការវា។

# តើអន្តរាគមន៍បឋមវ័យជាអ្វី?

សេវាអន្តរាគមន៍បឋមវ័យគឺជាសេវាអភិវឌ្ឍន៍ពិការភាព ដែលត្រូវបានផ្តល់ជូនក្រោមការមើលគ្រប់គ្រងជាសាធារណៈ ក្នុងបរិយាកាសធម្មតា។ សេវាកម្មទាំងនេះត្រូវបានបង្កើតឡើង ដើម្បីបំពេញសេចក្តីត្រូវការផ្នែកអភិវឌ្ឍន៍ពិការភាពរបស់ទារក ឬកូនក្មេងអាយុពីរបីឆ្នាំ ដែលមានលក្ខណសម្បត្តិទទួលជំនួយនេះ និងត្រូវបានបង្កើតឡើង ដើម្បីជួយឪពុកម្តាយឲ្យជួយកូនរបស់ពួកគាត់ក្នុងការអភិវឌ្ឍន៍កាយសម្បទា និងសិក្សារៀនសូត្រ។

សេវាអន្តរាគមន៍បឋមវ័យ (នៅក្នុងអំឡុងឆ្នាំដំបូងនៃជីវិតរបស់ក្មេង) អាចធ្វើឱ្យមានការផ្លាស់ប្តូរជាវិជ្ជមាន តាមរយៈការជួយលោកអ្នក៖

- ស្វែងរកសេវាកម្មនានា ដែលលោកអ្នកត្រូវការសម្រាប់កូនរបស់លោកអ្នក។
- ឲ្យយល់អំពីការលូតលាស់ចម្រើនវ័យនៃការអភិវឌ្ឍន៍កាយសម្បទារបស់កូនលោកអ្នក។
- ឲ្យអាចឧបត្ថម្ភការសិក្សារៀនសូត្រ និងការអភិវឌ្ឍន៍ និងការចូលរួមក្នុងកិច្ចការផ្ទះសម្បែង និងសកម្មភាពសហគមន៍របស់កូនលោកអ្នកដោយជោគជ័យ។

## តើគោលបំណងនៃសេវាអន្តរាគមន៍បឋមវ័យជាអ្វី?

គោលបំណងនៃសេវាអន្តរាគមន៍បឋមវ័យគឺដើម្បីពង្រឹងកម្លាំងគ្រួសារដែលមានស្រាប់ឲ្យរឹតតែរឹងមាំថែមទៀត តាមរយៈការផ្តល់កិច្ចសម្របសម្រួល, កិច្ចទ្រទ្រង់, ធនធាន, និងសេវាកម្មផ្សេងៗ ដើម្បីបង្កើនការធំធាត់របស់ក្មេងដែលមានពិការភាព និងបញ្ឈប់ឃីតយ៉ាវខាងផ្នែកអភិវឌ្ឍន៍កាយសម្បទា តាមរយៈការផ្តល់ឱកាសឲ្យពួកគេបានរៀនសូត្ររាល់ថ្ងៃ។

ដើម្បីផ្តល់លទ្ធភាពឱ្យគ្រួសារទាំងឡាយអាចមើលថែទាំកូនរបស់ពួកគេ ព្រមទាំងចូលរួមក្នុងសកម្មភាពគ្រួសារ និងសហគមន៍ទៅបាន, នោះគ្រួសារទាំងឡាយនឹងត្រូវតែ៖

- ដឹងនូវសិទ្ធិរបស់ពួកគេ។
- ចេះប្រាស្រ័យទាក់ទងអំពីសេចក្តីត្រូវការនានារបស់កូនពួកគេដោយប៉ិនប្រសប់។
- ជួយកូនពួកគេធ្វើការអភិវឌ្ឍន៍ និងរៀនសូត្រ។

ដើម្បីជួយក្មេងឱ្យសកម្ម ព្រមទាំងចេះចូលរួមដោយជោគជ័យគ្រប់ទីកន្លែង និងគ្រប់កាលៈទេសៈទៅបាន, នោះក្មេងនឹងត្រូវតែមានការលូតលាស់ល្អប្រសើរឡើងខាងផ្នែក៖

- ជំនាញការសង្គមកិច្ច-អារម្មណ៍ជាវិជ្ជមាន និងទំនាក់ទំនងសង្គមកិច្ច។
- ការទទួលបាន និងការប្រើប្រាស់ចំណេះដឹង និងជំនាញការនានា សរុបទាំងជំនាញការផ្នែកភាសា និងផ្នែកការប្រាស្រ័យទាក់ទងផង។
- ការប្រើប្រាស់អាកប្បកិរិយាសមរម្យ ដើម្បីជួបតាមសេចក្តីត្រូវការនានារបស់ពួកគេ។



## តើ Individuals with Disabilities Education Act (ច្បាប់អប់រំបុគ្គលដែលមានពិការភាព, IDEA) ជាអ្វី?

នៅឆ្នាំ 1986, រដ្ឋសភាសហរដ្ឋអាមេរិកបានធ្វើវិសោធនកម្មច្បាប់មួយ ដែលឥឡូវនេះត្រូវគេស្គាល់ជាទូទៅថា Individuals with Disabilities Education Act (ច្បាប់អប់រំបុគ្គលដែលមានពិការភាព, IDEA) ហើយបានបង្កើតកម្មវិធីមួយ ដើម្បីជួយជំរុញរដ្ឋនានាឱ្យបង្កើត និងប្រតិបត្តិប្រព័ន្ធសេវាអន្តរាគមន៍បឋមវ័យពាសពេញទូទាំងរដ្ឋ ដើម្បីបម្រើកុមារក្មេងខ្ចីដែលមានពិការភាព និងគ្រួសាររបស់ពួកគេ។ ច្បាប់នេះបានបង្កើតបទដ្ឋាន ដើម្បីឲ្យរដ្ឋនានាអនុវត្តតាមក្នុងការផ្តល់សេវាកម្មដល់បណ្តាគ្រួសារដែលមានទារក និងកូនក្មេងខ្ចីដែលមានពិការភាព។ រដ្ឋនីមួយៗមានសិទ្ធិធ្វើការសម្រេចមើលឡើងវិញជារៀងរាល់ឆ្នាំ ថាតើខ្លួននៅអាចបន្តផ្តល់សេវាអន្តរាគមន៍បឋមវ័យទៅតាមលក្ខខណ្ឌដែលមានចែងក្នុងច្បាប់ IDEA បានឬទេ។ កម្មវិធី Early Support for Infants and Toddlers (ឧបត្ថម្ភបឋមវ័យសម្រាប់ទារក និងកុមារវ័យក្មេង, ESIT) របស់ Department of Children, Youth, and Families (ក្រសួងកុមារ យុវជន និងគ្រួសារ, DCYF) គឺជាកម្មវិធីដឹកនាំកិច្ចសម្របសម្រួលនៃប្រព័ន្ធសេវាអន្តរាគមន៍បឋមវ័យពាសពេញទូទាំងរដ្ឋ។

សេវាអន្តរាគមន៍បឋមវ័យត្រូវបានរចនាឡើង សម្របទៅតាមសេចក្តីត្រូវការខាងផ្នែកអភិវឌ្ឍន៍កាយសម្បទារបស់កុមារម្នាក់ៗដែលមានលក្ខណសម្បត្តិទទួលជំនួយ ព្រមទាំងសេចក្តីត្រូវការរបស់គ្រួសារ ដែលទាក់ទងទៅនឹងការបង្កើនកិច្ចអភិវឌ្ឍន៍កាយសម្បទារបស់កុមារ។

បើលោកអ្នកត្រូវការអ្នកបកប្រែភាសាសញ្ញា, នោះគេត្រូវតែផ្តល់អ្នកបកប្រែភាសាសញ្ញាម្នាក់ជូនលោកអ្នក។ បើលោកអ្នកមិនចេះនិយាយភាសាអង់គ្លេស, នោះគេត្រូវតែផ្តល់អ្នកបកប្រែភាសាផ្ទាល់មាត់ម្នាក់ជូនលោកអ្នក, វៀរលែងតែគេគ្មានលទ្ធភាពទាល់តែសោះ ដើម្បីធ្វើកិច្ចការខាងលើនេះជូនលោកអ្នក។

# ចុះបើខ្ញុំមានសំណួរស្តីអំពីការអភិវឌ្ឍន៍កាយសម្បទារបស់កូនខ្ញុំ?

ចូរទូរស័ព្ទទាក់ទង family resources coordinator (បុគ្គលិកសម្របសម្រួលធនធានគ្រួសារ, FRC) ប្រចាំមូលដ្ឋានរបស់លោកអ្នក។ បុគ្គលិក FRC មានទីស្នាក់ការនៅក្នុងខោនធី ឬតំបន់រស់នៅនីមួយៗរបស់លោកអ្នក។ ការងាររបស់ពួកគេគឺដើម្បីជួយក្រុមគ្រួសាររបស់លោកអ្នកក្នុងការទទួលសេវាអន្តរាគមន៍បឋមវ័យដែលកូនរបស់លោកអ្នកអាចនឹងត្រូវការ។ ដើម្បីរកឈ្មោះ FRC ប្រចាំមូលដ្ឋានរបស់លោកអ្នក, ចូរទូរស័ព្ទទាក់ទងទៅកាន់ Family Health Hotline (ខ្សែទូរស័ព្ទឆ្លើយតបភ្លាមៗនៃបណ្តាញសុខភាពគ្រួសារ) តាមលេខ 1-800-322-2588។ លោកអ្នកអាចទូរស័ព្ទទាក់ទង ក្រសួងសុខាភិបាលមូលដ្ឋាន ឬមណ្ឌលសិក្សាធិការរបស់លោកអ្នកក៏បាន។

ចូរនិយាយជាមួយអ្នកផ្តល់សេវាថែទាំសុខភាពរបស់លោកអ្នកអំពីកង្វល់នានាដែលលោកអ្នកមាន។ ពួកគេអាចផ្តល់ការត្រួតពិនិត្យ ឬណែនាំអំពីធនធានផ្សេងៗជូនលោកអ្នក។ ប្រសិនបើលោកអ្នកពុំមានវេជ្ជបណ្ឌិត ហើយចង់បានពត៌មាន ឬជំនួយបន្ថែម, ចូរទូរស័ព្ទទាក់ទងទៅកាន់ Family Health Hotline (ខ្សែទូរស័ព្ទឆ្លើយតបភ្លាមៗនៃបណ្តាញសុខភាពគ្រួសារ) តាមលេខទូរស័ព្ទដែលបានចុះជូនខាងលើ។ លោកអ្នកមិនបាច់មានការបញ្ជូនពីវេជ្ជបណ្ឌិត ដើម្បីទៅទទួលសេវាអន្តរាគមន៍បឋមវ័យទេ។ ក្នុងឋានៈជាឪពុកម្តាយម្នាក់, លោកអ្នកមានសិទ្ធិអាចបញ្ជូនខ្លួនឯងទៅរកសេវាកម្មទាំងនេះបាន។

## តើការពិនិត្យត្រួសៗជាអ្វី?

ការពិនិត្យត្រួសៗ (screening) គឺជាការពិនិត្យឆាប់រហ័សដោយប្រើពេលខ្លី ដើម្បីវិនិច្ឆ័យមើលអំពីបែបបទដែលកូនរបស់លោកអ្នករៀន និងលូតលាស់វ័យ។ ការពិនិត្យត្រួសៗត្រូវតែបានធ្វើឡើងដោយមនុស្សដែលមានចំណេះដឹងខាងការកំណត់មើលអំពីបែបបទដែលកូនរបស់លោកអ្នកអភិវឌ្ឍន៍កាយសម្បទា។ បើការអភិវឌ្ឍន៍កាយសម្បទារបស់កូនលោកអ្នកមានបញ្ហាគួរកត់សម្គាល់, នោះបុគ្គលិក FRC របស់លោកអ្នកផ្តល់ពត៌មានជូនលោកអ្នកស្តីអំពីរបៀបយកកូនរបស់លោកអ្នកទៅទទួលការវាយតម្លៃមើលលម្អិតលើការអភិវឌ្ឍន៍របស់វា។



## តើការវាយតម្លៃដើមហេតុជាអ្វី?

ការវាយតម្លៃដើមហេតុ (evaluation) នឹងផ្តល់ការផ្តោតមើលជាលម្អិតលើការអភិវឌ្ឍន៍កាយសម្បទារបស់កូនលោកអ្នក។ ការវាយតម្លៃដើមហេតុនឹងធ្វើឡើងជាមួយលោកអ្នក, កូនរបស់លោកអ្នក, និងអ្នកមានវិជ្ជាជីវៈផ្នែកអន្តរាគមន៍បឋមវ័យ។

ការវាយតម្លៃដើមហេតុគឺផ្តោតមើលការអភិវឌ្ឍន៍លើផ្នែកសំខាន់ៗដូចតទៅ៖

- បញ្ញាញាណ – សមត្ថភាពក្នុងការរៀន និងបែបបទដែលកូនរបស់លោកអ្នករៀន
- សារពាង្គកាយ – សមត្ថភាពក្នុងការធ្វើចលនាផ្លូវកាយ, មើល, និងស្តាប់
- ការប្រាស្រ័យទាក់ទង – សមត្ថភាពក្នុងការយល់ភាសា និងការប្រាប់អំពីសេចក្តីត្រូវការ
- សង្គមកិច្ច និងមនោសញ្ចេតនា – សមត្ថភាពក្នុងការសេពគប់ជាមួយមនុស្សដទៃ
- ជំនាញសម្របខ្លួន – សមត្ថភាពក្នុងការស្លៀកពាក់ ញ៉ាំ និងមើលថែខ្លួនឯង។

ការវាយតម្លៃដើមហេតុគឺជាមធ្យោបាយក្នុងការពិនិត្យមើលថាតើកូនរបស់អ្នកមានលក្ខណសម្បត្តិទទួលសេវាអន្តរាគមន៍បឋមវ័យទេ។ ការវាយតម្លៃដើមហេតុនឹងធ្វើឡើងតែនៅពេលណាមានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីលោកអ្នកប៉ុណ្ណោះ ហើយមិនអស់ថ្លៃអីទាំងអស់ដល់លោកអ្នក។

## តម្រុយសម្រាប់ផែនការវាយតម្លៃដើមហេតុ៖

- ស្នើសុំការជួយផ្សេងៗពី family resources coordinator (បុគ្គលិកសម្របសម្រួលធនធានគ្រួសារ, FRC) របស់អ្នក។
- ស្នើសុំការឆ្លើយបំភ្លឺដល់សំណួរ ឬកង្វល់នានាដែលលោកអ្នកអាចនឹងមានស្តីអំពីការអភិវឌ្ឍន៍កាយសម្បទារបស់កូនលោកអ្នក។
- ចែករំលែកគ្រប់ពត៌មានដែលលោកអ្នកគិតថាមានសារសំខាន់ ដូចជា៖ ឯកសារវេជ្ជសាស្ត្រ, សៀវភៅកូនង៉ា, តារាងលូតលាស់វ័យ, ឬរបាយការណ៍ផ្សេងៗទៀត។
- សម្រេចមើលថាតើពេលណា ឬកន្លែងណាដែលងាយស្រួលសម្រាប់លោកអ្នក និងគ្រួសាររបស់លោកអ្នក។
- អញ្ជើញសមាជិកក្នុងគ្រួសារ, មិត្តភ័ក្តិ, ឬអ្នកឧបត្ថម្ភគាំទ្រឲ្យចូលរួម ប្រសិនបើលោកអ្នកមានបំណងចង់អញ្ជើញពួកគេ។
- ប្រាប់បុគ្គលិក FRC របស់លោកអ្នកឲ្យបានដឹង ប្រសិនបើលោកអ្នកត្រូវការអ្នកបកប្រែ ឬត្រូវការជំនួយដទៃៗទៀត។

បន្ទាប់ពីការវាយតម្លៃដើមហេតុបានបញ្ចប់ទៅ, លោកអ្នក និងបណ្តាសមាជិកនៃក្រុមការងាររបស់លោកអ្នកនឹងពិគ្រោះអំពីអាការដែលកូនរបស់លោកអ្នកកំពុងមាន ហើយនិងស្វែងយល់អំពីបញ្ហាផ្សេងៗ។ ប្រសិនបើមានករណីណាមួយដែលបង្ហាញថា កូនរបស់លោកអ្នកមានការយឺតយ៉ាវខាងផ្នែកអភិវឌ្ឍន៍, នោះកូនរបស់លោកអ្នកអាចនឹងមានលក្ខណសម្បត្តិទទួលសេវាអន្តរាគមន៍បឋមវ័យ។ លោកអ្នកមានជម្រើសអាចទទួល ឬមិនទទួលសេវាកម្មទាំងនេះបាន។

# តើនរណាជាអ្នកមានលក្ខណសម្បត្តិទទួលសេវាអន្តរាគមន៍បឋមវ័យក្នុងរដ្ឋ Washington?

ដើម្បីមានលក្ខណៈសម្បត្តិ, ក្មេងត្រូវតែមានបញ្ហាយឺតយ៉ាវផ្នែកអភិវឌ្ឍន៍កាយសម្បទា 25 ភាគរយ ឬបង្ហាញថាមាន គម្លាតបទដ្ឋានលូតលាស់ 1.5 ក្រោមវ័យរបស់វាយ៉ាងតិចណាស់ក្នុងចំណុចមួយ ឬច្រើននៃការអភិវឌ្ឍន៍កាយសម្បទារបស់វា។ ក្មេងក៏អាចមានលក្ខណសម្បត្តិដែរ ប្រសិនបើក្មេងរូបនោះមានវិបត្តិផ្លូវកាយឬផ្លូវសតិ, ដូចជាវិបត្តិជំងឺមិនគ្រប់ទឹកជាដើម, ដែលត្រូវបានគេស្គាល់ថា ជាកត្តាបង្កឲ្យមានបញ្ហាយឺតយ៉ាវក្នុងការអភិវឌ្ឍន៍កាយសម្បទា។

## តើការវាយតម្លៃគុណភាពសេវាកម្មជាអ្វី?

ការវាយតម្លៃគុណភាពសេវាកម្ម (assessment) ជាការកាយវាយតម្លៃដោយផ្អែកលើពត៌មានដែលទទួលបានពីលោកអ្នក, ពីមនុស្សដទៃៗដែលស្គាល់កូនរបស់លោកអ្នក, និងពីនីតិវិធីនានាដែលអ្នកផ្តល់សេវាអន្តរាគមន៍បឋមវ័យអាចនឹងប្រើប្រាស់ ដើម្បីស្វែងយល់អំពីអាកប្បកិរិយា និងការអភិវឌ្ឍន៍របស់កូនលោកអ្នកទៅតាមទម្លាប់ និងសកម្មភាពសាមញ្ញៗមួយចំនួន។ ការវាយតម្លៃគុណភាពសេវាកម្មគឺផ្តោតជាសំខាន់លើរបៀបរបបដែលកូនរបស់លោកអ្នករៀនបំណិនថ្មីៗ, របៀបដែលវាសេពគប់មនុស្សដទៃៗ, អ្វីដែលវាចូលចិត្ត និងអ្វីដែលធ្វើឲ្យវាតប់ប្រមល់ក្នុងចិត្ត ឬស្មុគស្មាញក្នុងការប្រតិបត្តិ។ ពត៌មានដែលប្រមូលបានពីការវាយតម្លៃគុណភាពសេវាកម្មនឹងជួយលោកអ្នក និងក្រុមការងាររបស់លោកអ្នកក្នុងការសម្រេចចិត្តថាតើលទ្ធផល (ការផ្លាស់ប្តូរ) បែបណា ដែលលោកអ្នកចង់ឃើញកើតមានឡើង និងសេវាកម្ម ព្រមទាំងការឧបត្ថម្ភដែលអាចជួយលោកអ្នកឈានទៅសម្រេចបានលទ្ធផលទាំងនោះ។

ការវាយតម្លៃគុណភាពសេវាកម្មក៏រួមមានផងដែរនូវទម្រង់ការមួយចំនួន ដែលត្រូវបានគេប្រើប្រាស់ជាប្រចាំដើម្បីកំណត់មើលវឌ្ឍនភាពរបស់កូនលោកអ្នកក្នុងការឈានទៅសម្រេចបានវឌ្ឍនភាពដែលត្រូវបានរំពឹងនោះ។



# តើនឹងមានអ្វីកើតឡើងជាបន្ទាប់មកទៀត?

## Individualized Family Service Plan (ផែនការសេវាគ្រួសារតម្រូវតាមស្ថានភាពបុគ្គល, IFSP)

ប្រសិនបើមានលក្ខណសម្បត្តិ, នោះកូនរបស់លោកអ្នកអាចនឹងទទួលបានសេវាអន្តរាគមន៍បឋមវ័យ IDEA។ លោកអ្នកនឹងត្រូវជួបជាមួយ family resources coordinator (បុគ្គលិកសម្របសម្រួលធនធានគ្រួសារ, FRC) និងជាមួយបណ្ដាអ្នកផ្ដល់សេវាថែទាំសុខភាពដទៃៗទៀត។ គ្រួសាររបស់លោកអ្នក, រួមជាមួយអ្នកដទៃៗទៀតនោះ, នឹងសរសេរតាក់តែងផែនការមួយ ដែលមានឈ្មោះថា Individualized Family Service Plan (ផែនការសេវាគ្រួសារតម្រូវតាមស្ថានភាពបុគ្គល, IFSP)។ ចូរធ្វើការជាមួយបុគ្គលិក FRC របស់អ្នកដើម្បីធានាថា ផែនការនេះបានឆ្លុះបញ្ចាំងអំពីកង្វល់, ផលប្រយោជន៍ និងតម្លៃគ្រួសាររបស់លោកអ្នក។

សេវាកម្មនឹងចាប់ផ្ដើមដំណើរការនៅពេលណាលោកអ្នកបានផ្ដល់សេចក្ដីយល់ព្រមលើផែនការ IFSP និងការផ្ដល់សិទ្ធិអនុញ្ញាតចំពោះសេវាកម្មទាំងប៉ុន្មានរួចរាល់ហើយ។

ផែនការ IFSP គឺជានីតិវិធីប្រតិបត្តិការមួយ ដែលប្រែប្រួលតាមកាលៈទេសៈជានិច្ច ដើម្បីឲ្យជួបតាមសេចក្ដីត្រូវការនានារបស់កូនលោកអ្នក និងគ្រួសារលោកអ្នក។ ផែនការនេះនឹងត្រូវឆ្លងកាត់ការពិនិត្យសើរើបានពិនិត្យឡើងវិញយ៉ាងហោចណាស់រៀងរាល់ប្រាំមួយខែម្ដង ហើយវានឹងត្រូវឆ្លងកាត់ការសរសេរតាក់តែងឡើងវិញរៀងរាល់ឆ្នាំ។



ផែនការ IFSP រួមមាន៖

- **កម្រិតវត្តកម្មបច្ចុប្បន្ន** – អ្វីដែលកូនរបស់លោកអ្នកកំពុងធ្វើឥឡូវនេះ។
- **សេចក្ដីថ្លែងការណ៍របស់គ្រួសារ** – សេចក្ដីថ្លែងការណ៍អំពីកង្វល់, អាទិភាព, និងធនធាននានារបស់គ្រួសារ; សេចក្ដីការណ៍របស់គ្រួសារលោកអ្នកគឺជាផ្នែកមួយសំខាន់នៃផែនការ IFSP, ប៉ុន្តែលោកអ្នកអាចជ្រើសរើសមិនធ្វើសេចក្ដីការណ៍នោះក៏បាន។
- **លទ្ធផល** – ការផ្លាស់ប្ដូរនានា ដែលលោកអ្នកចង់ឃើញកើតមានដល់កូន និងគ្រួសាររបស់លោកអ្នក។
- **សេវាអន្តរាគមន៍បឋមវ័យដែលត្រូវការ** – ញឹកញាប់ប៉ុនណា និងមានរយៈពេលយូរប៉ុនណា, តើវាកើតឡើងនៅទីណា, ហើយនរណាជាអ្នកចេញប្រាក់បង់ថ្លៃសេវាកម្មនេះ (មានប្រភពខុសៗគ្នាជាច្រើនដែលផ្ដល់មូលនិធិទ្រទ្រង់សេវាអន្តរាគមន៍បឋមវ័យ)។ លោកអ្នកអាចទទួល ឬបដិសេធសេវាកម្មណាមួយ ដែលគេផ្ដល់ជូនលោកអ្នកបាន (លើកលែងតែសេវាសម្របសម្រួលធនធានគ្រួសារ) ប្រសិនបើលោកអ្នកកំពុងចូលរួមក្នុងកម្មវិធីអន្តរាគមន៍បឋមវ័យ។
- **បរិស្ថានធម្មជាតិ** – សេចក្ដីថ្លែងការណ៍ស្ដីអំពីបរិស្ថានធម្មជាតិ ដែលក្នុងនោះ សេវាអន្តរាគមន៍បឋមវ័យនឹងត្រូវបានផ្ដល់ជូន។ ផែនការ IFSP ត្រូវតែបានបញ្ចូលនូវការកែតម្រូវជាលាយលក្ខណ៍អក្សរ ប្រសិនបើសេវាអន្តរាគមន៍នឹងមិនត្រូវបានគេផ្ដល់ជូននៅក្នុងបរិស្ថានធម្មជាតិទេនោះ។
- **រយៈកាល** – កំណត់ពេលដែលសេវាកម្មនឹងចាប់ផ្ដើម ហើយនឹងបញ្ចប់, និងកំណត់ពេលដែលលោកអ្នកនឹងត្រូវពិនិត្យមើលផែនការរបស់លោកអ្នកសារឡើងវិញ។
- **សេវាដទៃៗទៀតដែលត្រូវការ ដែលមិនបានឧបត្ថម្ភក្រោមច្បាប់ IDEA** – មនុស្ស ឬទីភ្នាក់ងារដែលអាចជួយលោកអ្នកក្នុងការស្វែងរកសេវាកម្មទាំងនេះ។
- **A family resources coordinator (បុគ្គលិកសម្របសម្រួលធនធានគ្រួសារ, FRC)** – ជនដែលមានឈ្មោះចុះក្នុងផែនការរបស់លោកអ្នក។
- **ផែនការអន្តរកាលមុនពេលឈានដល់អាយុ 3 ឆ្នាំ** – ការត្រួតពិនិត្យ និងការរៀបចំផែនការសម្រាប់សេវាកម្មក្រោយអាយុ 3 ឆ្នាំ។

អ្នកប្រហែលជាចង់អញ្ជើញសមាជិកដទៃៗទៀតក្នុងគ្រួសារ, មិត្តភ័ក្តិ, ឬអ្នកឧបត្ថម្ភគាំទ្រានានាមកចូលរួមកិច្ចប្រជុំពិភាក្សា។ សូមនាំយកពត៌មានទាំងឡាយស្ដីអំពីកូនរបស់លោកអ្នក ដែលលោកអ្នកគិតថាមានសារៈសំខាន់សម្រាប់កូនរបស់លោកអ្នក។

# តើនឹងមានអ្វីកើតឡើងនៅពេលបានអាយុ 3 ឆ្នាំ?

យ៉ាងហោចណាស់ប្រាំមួយទៅប្រាំបួនខែមុនពេលកូនរបស់លោកអ្នកឈានដល់អាយុ 3 ឆ្នាំ family resources coordinator (បុគ្គលិកសម្របសម្រួលធនធានគ្រួសារ, FRC) នឹងជួយលោកអ្នករៀបចំគម្រោងបន្តដំណើរទៅកាន់ដំណាក់កាលថ្មី ដើម្បីទទួលជំនួយពីអ្នកផ្តល់សេវា ឬពីទីភ្នាក់ងារផ្តល់សេវាបម្រើកូនរបស់លោកអ្នកបន្ទាប់ៗទៀត។ គម្រោងនេះអាចនឹងផ្លាស់ប្តូរទីកន្លែង ឬរបៀបដែលលោកអ្នកទទួលសេវាកម្ម។ នៅក្នុងករណីអន្តរាគមន៍បឋមវ័យ, ការផ្លាស់ប្តូរនេះត្រូវបានគេហៅថាអន្តរកម្ម (ឬការផ្លាស់ប្តូរពីដំណាក់កាលមួយទៅដំណាក់កាលមួយ)។ ច្បាប់ IDEA តម្រូវឲ្យលោកអ្នកមានផែនការជាលាយលក្ខណ៍អក្សរសម្រាប់អន្តរកម្មនេះ។ កិច្ចប្រជុំពិភាក្សាអំពីផែនការអន្តរកម្មត្រូវបានធ្វើឡើងយ៉ាងតិចណាស់ 90 ថ្ងៃមុនពេលដែលកូនរបស់លោកអ្នកឈានដល់អាយុ 3 ឆ្នាំ។ ផែនការអន្តរកម្មរបស់លោកអ្នកនឹងចែងបញ្ជាក់អំពីការអប់រំពិសេស ឬសេវាជំនួយផ្អែកលើមូលដ្ឋានសហគមន៍នានា ដែលកូនរបស់លោកអ្នកអាចនឹងត្រូវការ។

បុគ្គលិក FRC របស់លោកអ្នកនឹងស្នើសុំលោកអ្នកឲ្យចុះហត្ថលេខាលើទម្រង់បែបបទផ្តល់ការអនុញ្ញាតណាមួយ ដើម្បីឲ្យទីភ្នាក់ងារឬអ្នកផ្តល់សេវាបម្រើបន្ទាប់ៗទៀតអាចត្រូវបានទាក់ទងដើម្បីធ្វើផែនការអន្តរកម្ម។ កិច្ចប្រជុំពិភាក្សារវាងលោកអ្នក បុគ្គលិក FRC របស់លោកអ្នក, (បណ្តា) អ្នកផ្តល់សេវាកម្ម, និងមណ្ឌលសិក្សាធិការមូលដ្ឋាននឹងត្រូវបានរៀបចំឡើង។

មណ្ឌលសិក្សាធិការមូលដ្ឋាននឹងកំណត់មើលថាតើកូនរបស់លោកអ្នកមានលក្ខណសម្បត្តិសម្រាប់ចូលរៀនក្នុងកម្មវិធីអប់រំពិសេសបុរេសាលាឬទេ។ ពួកគេនឹងពិភាក្សាអំពីលទ្ធផលនានា ដែលទទួលបានពីតេស្តរបស់ពួកគេជាមួយលោកអ្នក ព្រមទាំងផ្តល់ជូនលោកអ្នកនូវពត៌មានស្តីអំពីសិទ្ធិរបស់លោកអ្នក។ ប្រសិនបើកូនរបស់លោកអ្នកមានលក្ខណសម្បត្តិ, នោះសេវាកម្មរបស់ពួកគេនឹងត្រូវបានផ្តល់ជូនតាមរយៈ Individualized Education Program (កម្មវិធីអប់រំពិសេសតម្រូវតាមស្ថានភាពបុគ្គល, IEP)។

បុគ្គលិក FRC របស់លោកអ្នកនឹងជួយលោកអ្នកក្នុងការរៀបចំគម្រោងទៅទទួលសេវាកម្មដទៃៗទៀតជាយថាហេតុ ប្រសិនបើកូនរបស់លោកអ្នកមិនមានលក្ខណសម្បត្តិសម្រាប់ចូលរៀនក្នុងកម្មវិធីអប់រំពិសេសបុរេសាលានោះទេ។

## តម្រុយសម្រាប់កិច្ចប្រជុំពិភាក្សាអន្តរកម្ម៖

- ខិតខំប្រមូលពត៌មានស្តីអំពីការផ្លាស់ប្តូរដែលបានស្នើឡើងឲ្យបានរឹតតែច្រើនរឹតតែល្អ។
- សាកសួរអំពីជម្រើសសម្រាប់កម្មវិធីផ្សេងៗ ដែលអាចមានបម្រើការជាយថាហេតុ។
- សាកសួរថាតើការហ្វឹកហ្វឺន និងឧបត្ថម្ភប្រភេទណាដែលកម្មវិធីផ្តល់ជូនគ្រួសារ។
- ពិនិត្យមើលកម្មវិធីថ្មីៗឲ្យបានជាក់លាក់មុននឹងធ្វើការផ្លាស់ប្តូរ។
- ស្នើសុំសម្ភារៈដែលមានសំណេរលាយលក្ខណ៍អក្សរ ហើយខិតខំសិក្សាស្វែងយល់អំពីនីតិវិធីសម្រាប់ការចុះឈ្មោះ និងការចូលរួមក្នុងកម្មវិធីថ្មី។
- ផ្តល់ពត៌មានពាក់ព័ន្ធនឹងកូនរបស់លោកអ្នកទៅបុគ្គលិកកម្មវិធីថ្មីឲ្យបានរឹតតែច្រើនរឹតតែល្អ។



# តើសិទ្ធិរបស់ខ្ញុំក្រោម Individuals with Disabilities Education Act (ច្បាប់អប់រំបុគ្គលដែលមានពិការភាព, IDEA) មានអ្វីខ្លះ?

*(នីតិវិធីការពារ)*

ច្បាប់ភាគច្រើនមានបញ្ញត្តិមាត្រា ដែលនិយាយអំពីសិទ្ធិសម្រាប់ពលរដ្ឋ, ឯច្បាប់ IDEA ក៏មិនខុសគ្នាដែរ។ family resources coordinator (បុគ្គលិកសម្របសម្រួលធនធានគ្រួសារ, FRC) នឹងប្រគល់ជូនលោកអ្នកនូវ “Individuals with Disabilities Education (ច្បាប់អប់រំបុគ្គលដែលមានពិការភាព, IDEA) មាត្រា Part C” នីតិវិធីការពារ (សិទ្ធិរបស់មាតាបិតា)” ដែលពណ៌នាអំពីសិទ្ធិរបស់លោកអ្នក។

## ឧទាហរណ៍អំពីសិទ្ធិរបស់លោកអ្នកក្រោមច្បាប់ IDEA ដោយរួមមានទាំងសិទ្ធិរបស់លោកអ្នកក្រោមការ៖

- ធ្វើជាអ្នកផ្តល់សេចក្តីសម្រេចចម្បង និងអវសានសម្រាប់កូនរបស់លោកអ្នក។
- ទទួលសេវាកម្មនានា ដែលរួមមាន៖
  - សេវាសម្គាល់មើលជាបឋមលើបញ្ហានានា/គំហើញរបស់កូន (Child Find)
  - សេវាវាយតម្លៃដើមហេតុពហុវិន័យទាន់ពេល និងការវាយតម្លៃគុណភាពសេវាកម្ម
  - សេវាកំណត់លក្ខណសម្បត្តិរបស់កូនលោកអ្នក
  - សេវាបុគ្គលិកសម្របសម្រួល/ការសម្របសម្រួលធនធានគ្រួសារ

## បើកូនរបស់លោកអ្នកមានលក្ខណសម្បត្តិ នោះលោកអ្នកមានសិទ្ធិ៖

- បង្កើត Individualized Family Service Plan (ផែនការសេវាគ្រួសារតម្រូវតាមស្ថានភាពបុគ្គល, IFSP)។
- ទទួលបានការសម្របសម្រួលធនធានគ្រួសារទៅតាមកាលៈទេសៈពីបុគ្គលិក FRC, រហូតដល់ថ្ងៃខួបកំណើតទីបីរបស់កូនលោកអ្នក។
- family resources coordinator (បុគ្គលិកសម្របសម្រួលធនធានគ្រួសារ, FRC) ណាផ្សេងម្នាក់ទៀត។
- ទទួលសេវាអន្តរាគមន៍បឋមវ័យដែលទាក់ទងទៅនឹងការអភិវឌ្ឍន៍កាយសម្បទារបស់កូនលោកអ្នក។
- ព្រមទទួល ឬបដិសេធមិនទទួលសេវាកម្មនានា ដែលកូន និងគ្រួសាររបស់លោកអ្នកនឹងទទួលទៅតាមសេចក្តីសម្រេច ដែលបានធ្វើឡើងតាមរយៈនីតិវិធី IFSP។
- បដិសេធសេវាកម្មខ្លះ ដែលបានផ្តល់អនុសាសន៍ណែនាំដោយក្រុមការងារ IFSP ហើយនៅតែទទួលបានសេវាកម្មដទៃៗទៀត (លើកលែងតែសេវា FRC)។
- ចូលរួមក្នុងកិច្ចប្រជុំពិភាក្សាទាំងអស់ ដែលពាក់ព័ន្ធសេវាអន្តរាគមន៍បឋមវ័យរបស់កូនលោកអ្នក និងការផ្លាស់ប្តូរក្នុងការចែកចាយសេវាកម្មនានា។
- ឲ្យគេបើកកិច្ចប្រជុំនៅចំពេលម៉ោង និងទីកន្លែង ដែលបានព្រមព្រៀងចំពោះគ្រួសាររបស់លោកអ្នក។
- ទទួលបានសេចក្តីជូនដំណឹង និងក្រដាសស្នាម IFSP នានាជាភាសាកំណើតរបស់លោកអ្នក ឬជាភាសាដែលត្រូវបានប្រើប្រាស់ជាប្រក្រតីក្នុងផ្ទះរបស់លោកអ្នក។





## លោកអ្នកក៏មានការការពារចំពោះឯកសារអន្តរាគមន៍បឋមវ័យនានារបស់កូនលោកអ្នកផងដែរ។ ការការពារទាំងនេះរួមមានសិទ្ធិរបស់លោកអ្នកក្នុងការ៖

- ត្រួតពិនិត្យឯកសារនានា និងស្នើសុំធ្វើការកែប្រែឯកសារទាំងនោះ។
- ទទួលបានសំណៅចម្លងនៃឯកសារទាំងនោះ។
- ឲ្យគេប្រាប់អំពីប្រភេទ និងទីកន្លែងដែលគេប្រមូល, រក្សាទុក, ឬប្រើប្រាស់ពត៌មានក្នុងកម្មវិធី, តើមនុស្សណាខ្លះក្នុងកម្មវិធីនេះមានសិទ្ធិមើលឯកសារទាំងនោះ, និងតើពួកគេមើលឯកសារទាំងនោះនៅពេលណា។
- ស្នើសុំពត៌មានស្តីអំពីថាតើមនុស្សណាខ្លះបានមើលឯកសារ ឬសំណៅចម្លងនៃឯកសារទាំងនោះ។
- តវ៉ាឲ្យគេកែប្រែពត៌មានក្នុងឯកសារណាមួយ ដែលលោកអ្នកជឿថា មិនសុក្រឹតត្រឹមត្រូវ ឬនាំឲ្យមានការយល់ច្រឡំ ឬល្មើសនឹងសិទ្ធិជីវភាពឯកជន ឬសិទ្ធិរបស់កូន និងគ្រួសាររបស់លោកអ្នក។ ឯកសារអន្តរាគមន៍បឋមវ័យនានារបស់កូនលោកអ្នករួមមាន, ក្នុងចំណោមក្រដាសស្នាមដទៃ៖
  - ឯកសារពិនិត្យត្រួសៗ
  - ឯកសារវាយតម្លៃដើមហេតុ
  - ពត៌មានវាយតម្លៃគុណភាពសេវាកម្ម
  - ឯកសារកំណត់មើលលក្ខណៈសម្បត្តិ
  - ពត៌មានទាំងអស់ដែលជាផ្នែកនៃផែនការ IFSP

## ពត៌មានស្តីអំពីគ្រួសាររបស់លោកអ្នកត្រូវបានរក្សាទុកជាសម្ងាត់។ លោកអ្នកមានសិទ្ធិក្នុងការ៖

- ឲ្យគេរក្សាទុកជាសម្ងាត់នូវពត៌មានផ្ទាល់ខ្លួន និងពត៌មានទាំងឡាយដែលអាចបង្ហាញចេញអត្តសញ្ញាណសម្គាល់ខ្លួន ដែលរួមមាន៖
  - ឈ្មោះកូនលោកអ្នក, ឈ្មោះលោកអ្នក ឬឈ្មោះសមាជិកដទៃៗក្នុងគ្រួសារ។
  - អាសយដ្ឋានរបស់កូនលោកអ្នក។
  - ភិនភាគសម្គាល់ខ្លួន ឬពត៌មានដទៃៗទៀតដែលអាចបង្ហាញចេញអត្តសញ្ញាណសម្គាល់ខ្លួនរបស់កូនលោកអ្នក ដោយកម្រិតណាមួយជាយថាហេតុ។
- ស្នើសុំបទបញ្ជាផ្ទៃក្នុងប្រចាំមូលដ្ឋាន និងនីតិវិធីស្តីអំពីបែបបទដែលភាពលាក់ការសម្ងាត់ត្រូវបានគេការពារ។
- ផ្តល់ការយល់ព្រមជាលាយលក្ខណ៍អក្សរសម្រាប់ការប្តូរ ឬការចែករំលែកពត៌មាន ឬឯកសារនានា។

បន្ថែមលើសិទ្ធិមាតាបិតា/គ្រួសារ, កូនៗមានសិទ្ធិមានឪពុកឬម្តាយតាងនាម ប្រសិនបើ៖

- គេមិនស្គាល់ឪពុកឬម្តាយ។
- អ្នកផ្តល់សេវាបម្រើ/ ទីភ្នាក់ងារសាធារណៈ, ក្រោយបានប្រឹងប្រែងអស់អំពីសមត្ថភាព, មិនអាចរកឪពុកឬម្តាយឃើញ។
- កុមាររូបនេះជាបាលិតរបស់រដ្ឋ (កូនក្រោមការគ្រប់គ្រងរបស់រដ្ឋ)។



# ចុះបើខ្ញុំមិនយល់ស្របតាមសេចក្ដីសម្រេចណាមួយស្ដីអំពីសេវាកម្មរបស់កូនខ្ញុំ ឬរបស់គ្រួសារខ្ញុំ?

សូមនិយាយជាមួយ family resources coordinator (បុគ្គលិកសម្របសម្រួលធនធានគ្រួសារ, FRC) របស់លោកអ្នកអំពីបញ្ហានេះ។ ប្រសិនបើការនោះមិនដំណើរការល្អទេ ឬលោកអ្នកមានពុំមានអារម្មណ៍កក់ក្ដៅទេ, នោះលោកអ្នកអាចជ្រើសរើសប្រើប្រាស់ជម្រើសណាមួយ ឬទាំងអស់ដូចតទៅ៖

- **ការសម្រុះសម្រួល** – ការសម្រុះសម្រួល (Mediation) នឹងត្រូវបានផ្ដល់ជូនលោកអ្នកដោយឥតគិតថ្លៃ ដើម្បីជួយដោះស្រាយវិវាទ។ ការសម្រុះសម្រួលត្រូវបានផ្ដល់ជូនទុកជានីតិវិធីជំនួសសវនាការរដ្ឋបាលផ្លូវការ។ ការសម្រុះសម្រួលគឺជានីតិវិធីស្ម័គ្រចិត្ត។
- **សេវាគាំពារ** – នេះគឺជាកម្មវិធី ដែលនឹងផ្ដល់ជូនលោកអ្នកនូវពត៌មាន ហើយនឹងជួយលោកអ្នករៀបចំគម្រោងការដោះស្រាយបញ្ហា។ អង្គការគាំពារមួយពីអង្គការ **PAVE** (សូមមើលទំព័រទី **11**)។ បុគ្គលិក **FRC** របស់លោកអ្នកអាចផ្ដល់ជូនលោកអ្នកនូវពត៌មានស្ដីអំពីសេវាគាំពារក្នុងតំបន់របស់លោកអ្នក។
- **សវនាការត្រឹមត្រូវតាមនីតិវិធី (នីតិវិធីដោះស្រាយបណ្ដឹង)** – នេះគឺជាសវនាការផ្លូវការ ឬនីតិវិធីដោះស្រាយបណ្ដឹងមួយ ដែលប្រតិបត្តិឡើងដោយមន្ត្រីសវនាការរដ្ឋបាល។ សេចក្ដីស្នើសុំសវនាការរដ្ឋបាលត្រូវតែបានធ្វើឡើងជាលាយលក្ខណ៍អក្សរ ព្រមទាំងរួមមាននូវបទបណ្ដឹងផង។ ចូរចារខ្ទងសេចក្ដីស្នើសុំនេះជូនទៅនាយកនៃអ្នកផ្ដល់សេវាអន្តរាគមន៍បឋមវ័យ ឬអ្នកមៅការផ្ដល់សេវាអន្តរាគមន៍បឋមវ័យប្រចាំមូលដ្ឋានរបស់លោកអ្នក។ បុគ្គលិក FRC របស់លោកអ្នកអាចផ្ដល់ជូនលោកអ្នកនូវឈ្មោះ និងអាសយដ្ឋានរបស់ពួកគេ ឬលោកអ្នកអាចផ្ញើអ៊ីមែលទៅ **esit@dcyf.wa.gov** ហើយបន្ទាប់មកចូរស្នើសុំឲ្យពួកគេជួយ។

ឪពុកឬម្ដាយ, មនុស្សណាម្នាក់ ឬអង្គការណាមួយអាចដាក់ពាក្យបណ្ដឹងរដ្ឋបាលបាន ប្រសិនបើពួកគេគិតថា ទីភ្នាក់ងារណាមួយ ឬអ្នកផ្ដល់សេវាអន្តរាគមន៍បឋមវ័យណាម្នាក់បានប្រព្រឹត្តិល្មើសលក្ខខណ្ឌតម្រូវរបស់ច្បាប់។ បណ្ដឹងត្រូវតែបានធ្វើឡើងជាលាយលក្ខណ៍អក្សរ, ចុះហត្ថលេខាហើយនឹងអមភ្ជាប់ដោយអង្គហេតុនានាអំពីបណ្ដឹងនេះ។

ផ្ញើបណ្ដឹងនេះទៅកាន់៖

**Early Support for Infants and Toddlers (កម្មវិធីឧបត្ថម្ភបឋមវ័យសម្រាប់ទារក និងកុមារវ័យក្មេង) Department of Children, Youth, and Families (ក្រសួងកុមារ យុវជន និងគ្រួសារ)**
PO Box 40970
Olympia, WA 98504-0970

បណ្ដឹងនឹងត្រូវបានគេត្រួតពិនិត្យមើល ហើយសេចក្ដីឆ្លើយតបជាលាយលក្ខណ៍អក្សរនឹងត្រូវគេផ្ញើជូនលោកអ្នកនៅក្នុងរយៈពេល 60 ថ្ងៃ។



# តើខ្ញុំអាចទៅរកជំនួយ ឬពត៌មានពិស្តារបន្ថែមនៅទីណា?

អង្គការ ឬក្រុមនានាខាងក្រោមនេះអាចផ្តល់ពត៌មានពិស្តារបន្ថែម, ជំនួយ និងការឧបត្ថម្ភ៖

### Family Health Hotline (ខ្សែទូរស័ព្ទឆ្លើយតបភ្លាមៗនៃបណ្តាញសុខភាពគ្រួសារ)

1-800-322-2588

**www.withinreachwa.org**

បណ្តាញទូរស័ព្ទឆ្លើយតបភ្លាមៗនេះអាចផ្តល់ពត៌មានបច្ចុប្បន្នស្តីអំពីធនធានអន្តរាគមន៍បឋមវ័យសាធារណៈ និងឯកជន, ដែលរួមមាន Family Resources Coordinators (បុគ្គលិកសម្របសម្រួលធនធានគ្រួសារ, FRC)។ វាក៏រួមមានទាំងពត៌មានស្តីអំពីការចាក់ថ្នាំបង្ការរោគ, អាហារបត្ថម្ភ, និងសេវាសុខភាពកុមារដទៃទៀត ដែលមានបម្រើការក្នុងរដ្ឋ Washington ផងដែរ។

---

### Department of Children, Youth, and Families (ក្រសួងកុមារ យុវជន និងគ្រួសារ, DCYF) កម្មវិធី Early Support for Infants and Toddlers (ឧបត្ថម្ភបឋមវ័យសម្រាប់ទារក និងកុមារវ័យក្មេង, ESIT)

អ៊ីមែល៖ **esit@dcyf.wa.gov**

**www.dcyf.wa.gov**

គ្រប់គ្រងប្រព័ន្ធ IDEA, សេវាអន្តរាគមន៍បឋមវ័យពាសពេញទូទាំងរដ្ឋឈ Part C។

---

### មាតាបិតាជាមួយនឹងមាតាបិតា

1-800-821-5927

**www.arcwa.org**

បណ្តាញមាតាបិតាទូទាំងរដ្ឋ ដែលផ្តល់ការទ្រទ្រង់វិបត្តិផ្លូវអារម្មណ៍ និងពត៌មានផ្សេងៗដល់បណ្តាមាតាបិតា ដែលមានកូនក្មេងខ្ចីមានពិការភាព ឬការយឺតយ៉ាវខាងផ្នែកអភិវឌ្ឍន៍កាយសម្បទា។

### បណ្តាញឪពុកនៃរដ្ឋ Washington

425-747-4004 លេខភ្ជាប់បន្ត 218

**https://fathersnetwork.org**

គាំពារ, និងផ្តល់ការទ្រទ្រង់ និងធនធានសម្រាប់, បុរសគ្រប់រូប និងគ្រួសាររបស់ពួកគេ ដែលមានកូនត្រូវការជំនួយពិសេស។

---

### Washington PAVE (Partnerships for Action, Voices for Empowerment) (ភាពជាដៃគូសម្រាប់សកម្មភាព, សំឡេងដើម្បីពង្រឹងអំណាច)

1-800-5PARENT

**wapave.org**

មជ្ឈមណ្ឌលពត៌មាន និងបណ្តុះបណ្តាលចំណេះដឹងមាតាបិតា ដែលផ្តល់ជំនួយដល់បណ្តាគ្រួសារដែលមានកូនមានពិការភាពពីកំណើតរហូតដល់វ័យយុវភាព។



# តើខ្ញុំអាចចូលរួមឲ្យកាន់តែច្រើនថែមទៀតដោយរបៀបណា?

លោកអ្នកមានតួនាទីសំខាន់ណាស់ក្នុងការរៀបចំផែនការ និងការបង្កើតកម្មវិធី និងសេវាកម្មនានាសម្រាប់កូនរបស់លោកអ្នក។ លោកអ្នកក៏អាចចូលរួមក្នុងការរៀបចំផែនការស្តីអំពីរបៀបដែលសហគមន៍របស់លោកអ្នកផ្តល់សេវាបម្រើផងដែរ។

ការរៀបចំផែនការនេះត្រូវបានធ្វើឡើងនៅកម្រិតថ្នាក់ខោនធីតាមរយៈ County Interagency Coordinating Councils (ក្រុមប្រឹក្សាសម្របសម្រួលអន្តរទីភ្នាក់ងារខោនធី, CICCs)។ CICC នីមួយៗត្រូវបានតម្រូវឲ្យមានមាតាបិតាចូលរួមជាសមាជិកក្នុងក្រុមប្រឹក្សា។ តាមរយៈការរួមសាមគ្គីជាមួយបណ្តាសមាជិកដទៃៗទៀត, មាតាបិតាបានជួយធ្វើការអារកាត់អំពីរបៀប ដែលនាំឲ្យសេវាកម្មទាំងឡាយអាចកកើតឡើងប្រកបដោយប្រសិទ្ធភាពខ្ពស់។ កិច្ចប្រជុំរបស់ CICC បើកចំហជាទូទៅសម្រាប់សាធារណជន។

យើងក៏មាន State Interagency Coordinating Council (ក្រុមប្រឹក្សាសម្របសម្រួលអន្តរទីភ្នាក់ងាររដ្ឋ, SICC) ផងដែរ។ ក្រុមប្រឹក្សានេះក៏ត្រូវតែមានតំណាងពីមាតាបិតាផងដែរ។ កិច្ចប្រជុំរបស់ SICC បើកចំហជាទូទៅសម្រាប់សាធារណជន។ ដើម្បីស្វែងយល់ពត៌មានពិស្តារអំពីពេលវេលា និងទីកន្លែងប្រជុំ, សូមអញ្ជើញទាក់ទងfamily resources coordinator (បុគ្គលិកសម្របសម្រួលធនធានគ្រួសារ)របស់លោកអ្នក, ESIT, ឬសូមអញ្ជើញចូលទៅកាន់គេហទំព័រ **www.dcyf.wa.gov**។

កូនសៀវភៅនេះគឺជាសេចក្តីសង្ខេបស្តីអំពីកម្មវិធី Early Support for Infants and Toddlers (ឧបត្ថម្ភបឋមវ័យសម្រាប់ទារក និងកុមារវ័យក្មេង) របស់រដ្ឋ Washington។ សម្រាប់ពត៌មានលម្អិតពិស្តារស្តីអំពីផែនការដែលត្រូវបានអនុម័តរបស់រដ្ឋ Washington ក្រោមច្បាប់ IDEA ឬពត៌មានពិស្តារអំពី CICC របស់លោកអ្នក ឬ SICC, សូមទាក់ទងកម្មវិធី Early Support for Infants and Toddlers (ឧបត្ថម្ភបឋមវ័យសម្រាប់ទារក និងកុមារវ័យក្មេង) របស់រដ្ឋ Washington តាមអ៊ីមែល **esit@dcyf.wa.gov**។

**www.dcyf.wa.gov**



# ពាក្យនោះមានន័យដូចម្ដេច? (សទ្ទានុក្រម)

### សវនាការរដ្ឋបាល
នីតិវិធីផ្លូវការដែលត្រូវបានធ្វើឡើងជាមួយមនុស្សអព្យាក្រឹត, មន្ត្រីសវនាការ, ដែលស្ដាប់ការបង្ហាញភស្ដុតាង និងការជជែកអះអាងរបស់មាតាបិតា/គ្រួសារ និងទីភ្នាក់ងារនានា បន្ទាប់មកវិនិច្ឆ័យថាតើនរណាត្រូវ ហើយនរណាត្រូវតែធ្វើអ្វី។

### ការវាយតម្លៃគុណភាពសេវាកម្ម
ទម្រង់ការវាស់ស្ទង់ប្រសិទ្ធភាពសេវាកម្មជាមូលដ្ឋាន ដែលត្រូវបានប្រើប្រាស់ដោយបណ្ដាអ្នកជំនាញការដែលមានគុណសម្បត្តិជាប់រហូតពេញក្នុងរយៈកាលនៃការផ្ដល់សេវាអន្តរាគមន៍បឋមវ័យរបស់ក្មេង ដើម្បីវិភាគរកសេចក្ដីត្រូវការពិសេសរបស់ក្មេង; ធនធាន, អាទិភាព, និងបញ្ហាខ្វល់ខ្វាយរបស់គ្រួសារ ដែលពាក់ព័ន្ធការអភិវឌ្ឍន៍កាយសម្បទារបស់ក្មេង; និងលក្ខណៈ និងវិសាលភាពនៃសេវាអន្តរាគមន៍បឋមវ័យ ដែលត្រូវបានតម្រូវជាចាំបាច់ ដើម្បីឲ្យជួបតាមសេចក្ដីត្រូវការទាំងនេះ។

### ឧបករណ៍បច្ចេកវិជ្ជាជំនួយ
វត្ថុ ឧបករណ៍ ឬប្រព័ន្ធផលិតផលណាមួយ ដែលត្រូវបានប្រើប្រាស់ដើម្បីបង្កើន, រក្សា, ឬលើកស្ទួយសមត្ថភាពរបស់កូនលោកអ្នកក្នុងការធ្វើអ្វីមួយ (ឧទាហរណ៍៖ ការបរិភោគ, ការនិយាយប្រាស្រ័យទាក់ទង, ការធ្វើចលនាផ្លូវរាងកាយ។ល។)។

### សេវាបច្ចេកវិជ្ជាជំនួយ
សេវាកម្មដែលជួយក្មេងមានពិការភាពដោយផ្ទាល់ ដើម្បីជ្រើសរើស, យក, ឬប្រើប្រាស់ឧបករណ៍បច្ចេកវិជ្ជាជំនួយណាមួយ។

### គំហើញរបស់កូន
រួមមានការធ្វើវិភាគរកវិបត្តិ, ការពិនិត្យត្រួសៗ, ការបញ្ជូន, ការសម្របសម្រួលសេវាផ្ដួចផ្ដើមក្នុងវ័យបឋម។

### អន្តរាគមន៍បឋមវ័យ
ចង្កោមប្រមូលផ្ដុំនៃសេវាកម្មផ្សេងៗ ដែលផ្ដល់ដោយទីភ្នាក់ងារសាធារណៈ និងឯកជន ហើយត្រូវបានបង្កើតឡើងដោយច្បាប់ ដើម្បីទ្រទ្រង់ក្មេងដែលមានលក្ខណសម្បត្តិ និងគ្រួសាររបស់ពួកគេ ក្នុងការបង្កើនអាទិភាពរបស់ក្មេង សម្រាប់ការលូតលាស់ចម្រើនវ័យ និងការអភិវឌ្ឍន៍កាយសម្បទាពីកំណើតរហូតដល់អាយុ 3 ឆ្នាំ។

### ការវាយតម្លៃដើមហេតុ
ទម្រង់ការវាស់ស្ទង់រកដើមហេតុនៃជំងឺ ដែលត្រូវបានប្រើប្រាស់ដោយបណ្ដាអ្នកជំនាញការដែលមានគុណសម្បត្តិ ដើម្បីកំណត់ការផ្ដួចផ្ដើម និងការបន្តលក្ខណសម្បត្តិរបស់ក្មេង, ដែលផ្ដោតជាសំខាន់លើការកំណត់មើលស្ថានភាពរបស់ទារក ឬកុមារវ័យក្មេង លើគ្រប់ចំណុចអភិវឌ្ឍន៍កាយសម្បទារបស់ក្មេង; បញ្ញាញាណ, សង្គមកិច្ច/មនោសញ្ចេតនា, សារពាង្គកាយ (សរុបទាំងចក្ខុវិញ្ញាណ និងសោតវិញ្ញាណ), ការប្រាស្រ័យទាក់ទង, និងកោសល្យសមស្រប។

### ការថែទាំផ្ដោតលើគ្រួសារ
គោលការណ៍ដែលជួយជំរុញឪពុកម្ដាយឲ្យទៅជាអ្នកធ្វើសេចក្ដីសម្រេចចម្បង ព្រមទាំងបង្កើតភាពជាដៃគូរវាងឪពុកម្ដាយ និងពួកអ្នកជំនាញការ។

### សេចក្ដីថ្លែងការណ៍របស់គ្រួសារ
លិខិតណែនាំរបស់គ្រួសារស្ដីអំពីកង្វល់, អាទិភាព, និងធនធាននានារបស់គ្រួសារ ដែលបានបញ្ចូលក្នុង Individualized Family Service Plan (ផែនការសេវាគ្រួសារតម្រូវតាមស្ថានភាពបុគ្គល, IFSP)។

### Individualized Family Service Plan (ផែនការសេវាគ្រួសារតម្រូវតាមស្ថានភាពបុគ្គល, IFSP)
ផែនការលាយលក្ខណ៍អក្សរសម្រាប់ការផ្ដល់សេវាអន្តរាគមន៍បឋមវ័យ និងសេវាផ្សេងៗទៀតដល់ក្មេងដែលមានលក្ខណសម្បត្តិ និងគ្រួសាររបស់ពួកគេ ដែល៖ (1) ត្រូវបានបង្កើតឡើងរួមគ្នាដោយគ្រួសាររបស់ក្មេង និងអ្នកជំនាញការសមស្របនានា; (2) ផ្អែកលើការវាយតម្លៃដើមហេតុ និងការវាយតម្លៃគុណភាពសេវាកម្មពហុវិន័យរបស់ក្មេង និងគ្រួសារ; (3) មានលិខិតណែនាំរបស់គ្រួសារស្ដីអំពីធនធាន, អាទិភាព, និងកង្វល់នានា ប្រសិនបើគ្រួសារចង់ធ្វើលិខិត; និង (4) រួមមានសេវាចាំបាច់នានា ដើម្បីបង្កើនការអភិវឌ្ឍន៍កាយសម្បទារបស់ក្មេង និងសមត្ថភាពរបស់គ្រួសារក្នុងការជួបតាមសេចក្ដីត្រូវការនានាខាងផ្នែកអភិវឌ្ឍន៍កាយសម្បទារបស់ក្មេង។

### ទារក និងកុមារវ័យក្មេងដែលមានពិការភាព
ក្មេងពីកំណើតរហូតដល់អាយុ 3 ឆ្នាំ ដែលមានលក្ខណសម្បត្តិទទួលសេវាអន្តរាគមន៍បឋមវ័យ ពីព្រោះពួកគេកំពុងជួបប្រទះនឹងវិបត្តិគម្លាតបទដ្ឋាន 1.5 ឬវិបត្តិយឺតយ៉ាវខាងផ្នែកអភិវឌ្ឍន៍កាយសម្បទាយ៉ាងតិច 25 ភាគរយ ក្នុងចំណុចមួយ ឬច្រើនដូចតទៅ៖ បញ្ញាញាណ, សារពាង្គកាយ, ការប្រាស្រ័យទាក់ទង, សង្គមកិច្ច/មនោសញ្ចេតនា, ឬកោសល្យសម្រប; ឬត្រូវបានរកឃើញថាមានវិបត្តិសុខភាពផ្លូវកាយ ឬផ្លូវសតិ ដែលទំនងជានឹងនាំឲ្យមានវិបត្តិយឺតយ៉ាវខាងផ្នែកអភិវឌ្ឍន៍កាយសម្បទាកម្រិតខ្ពស់។

### ការសម្រុះសម្រួល
នីតិវិធីក្រៅផ្លូវការដែលក្នុងនោះ មនុស្សដែលមានចំណេះដឹងខាងផ្នែកដោះស្រាយជម្លោះ, ដែលមិនលំអៀង, អាចនឹងជួយភាគីទំនាស់ ដើម្បីស្វែងរកច្រកចេញពីភាពមិនចុះសម្រុងនានារបស់ពួកគេ ហើយរកដំណោះស្រាយដែលអាចទទួលយកបានណាមួយ ជូនភាគីទាំងអស់។

### ពហុវិន័យ, វិជ្ជាជីវៈ
បរិបទដែលមានផ្នែកវិន័យ ឬវិជ្ជាជីវៈលើសពីពីរឡើងទៅក្នុងបទដ្ឋាននៃសេវាកម្មសមាហរណកម្ម និងសេវាសម្របសម្រួល ដែលរួមមានទាំងសកម្មភាពវាយតម្លៃដើមហេតុ និងសកម្មភាពវាយតម្លៃគុណភាពសេវាកម្ម, ហើយនិងការបង្កើតផែនការ IFSP។

### បរិស្ថានធម្មជាតិ
របៀបរៀបរយដែលត្រូវទៅតាមទម្លាប់ធម្មជាតិ ឬទម្លាប់ធម្មតាសម្រាប់បណ្ដាក្មេងដែលគ្មានពិការភាព ដែលមានវ័យស្របាលគ្នានឹងក្មេងដែលមានពិការភាពរូបនេះ។ របៀបរៀបរយនេះអាចរួមមានរបៀបរៀបរយតាមផ្ទះ, តាមភូមិ, ឬតាមសហគមន៍។

### លទ្ធផល
របាយការណ៍ស្ដីអំពីការផ្លាស់ប្ដូរនានា ដែលលោកអ្នកចង់ឃើញក្នុងកូន ឬគ្រួសាររបស់លោកអ្នក ដែលជាលទ្ធផលទទួលបានពីសេវាអន្តរាគមន៍បឋមវ័យ។ របាយការណ៍ទាំងនេះគឺជាផ្នែកនៃ IFSP របស់លោកអ្នក។

### ការពិនិត្យត្រួសៗ
តារាងពិនិត្យ ឬទម្រង់វាស់ស្ទង់រហ័សស្ដីអំពីការអភិវឌ្ឍន៍កាយសម្បទារបស់កូនលោកអ្នក ដើម្បីពិនិត្យមើលថាតើគេចាំបាច់ត្រូវការទម្រង់ការវាយតម្លៃដើមហេតុ ដើម្បីពិនិត្យមើលអាការរបស់ក្មេងជាលម្អិតឬទេ។

### ឪពុកឬម្ដាយតាងនាម
មនុស្សម្នាក់ដែលបានចាត់តាំងដោយទីភ្នាក់ងារនៃអាជ្ញាធរមូលដ្ឋាន ឬអាជ្ញាធររដ្ឋ ដើម្បីធ្វើកិច្ចការជំនួសឪពុកឬម្ដាយ ឬអ្នកអាណាព្យាបាលក្នុងបុព្វហេតុការពារសិទ្ធិរបស់ក្មេងនៅក្នុងការធ្វើសេចក្ដីសម្រេចនានា។

### ផែនការអន្តរកម្ម
ផែនការដែលបានបង្កើតឡើងសម្រាប់កូនរបស់លោកអ្នក នៅពេលចាកចេញពីកម្មវិធីសេវាអន្តរាគមន៍បឋមវ័យ ពេលបានអាយុ 3 ឆ្នាំ។

# ការទទួលស្គាល់

ក្រុមរៀបចំគោលការណែនាំគ្រួសារ, គណៈកម្មការរបស់ State Interagency Coordinating Council (ក្រុមប្រឹក្សាសម្របសម្រួលអន្តរទីភ្នាក់ងាររដ្ឋ, SICC) បានចងក្រងកូនសៀវភៅនេះ។

គោលបំណងរបស់គណៈកម្មការនេះគឺដើម្បីជួយមាតាបិតារបស់ទារក និងកុមារវ័យក្មេងដែលមានពិការភាពឲ្យអំពីសេវាអន្តរាគមន៍បឋមវ័យក្រោម Individuals with Disabilities Education Act (ច្បាប់អប់រំបុគ្គលដែលមានពិការភាព, IDEA)។

សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់បណ្តាសមាជិកគណៈកម្មការ ដែលបានចំណាយពេលដើម្បីចងក្រងសៀវភៅណែនាំនេះឡើង៖

**Donna White**, ប្រធាន

Department of Health, Maternal and Child Health (ក្រសួងសុខាភិបាល សុខភាពមាតា និងទារក)

**Catherine Davis**

Us–Qwed–Eeth, Puyallup កុលសម្ព័ន្ធ គម្រោងចាប់ពីកើតរហូតដល់ប្រាំមួយឆ្នាំ

**Heather Hebdon**

គម្រោង Specialized Training of Military Parents (បណ្តុះបណ្តាលឯកទេសសម្រាប់ឪពុកម្តាយដែលបម្រើយោធា, STOMP)

**Kathy Hormann**

មជ្ឈមណ្ឌលអភិវឌ្ឍន៍កុមារ, សាំនើរ

**Cassie Johnston**

Washington PAVE, បុគ្គលិកសម្របសម្រួលការចូលរួមរបស់មាតាបិតា

**Lynne Leeper**

Washington PAVE, គម្រោងបណ្តុះបណ្តាលមាតាបិតា

**Melanie Stafford**

Us–Qwed–Eeth, Puyallup កុលសម្ព័ន្ធ គម្រោងចាប់ពីកើតរហូតដល់ប្រាំមួយឆ្នាំ

**Kathy Blodgett**, បុគ្គលិក

Department of Social and Health Services (ក្រសួងសេវាសុខាភិបាល និងសេវាសង្គមកិច្ច), អតីតកម្មវិធីអន្តរាគមន៍បឋមវ័យសម្រាប់ទារក និងកុមារវ័យក្មេងនៃរដ្ឋ Washington

**Barbie Faubion**, បុគ្គលិក

Department of Social and Health Services (ក្រសួងសេវាសុខាភិបាល និងសេវាសង្គមកិច្ច), អតីតកម្មវិធីអន្តរាគមន៍បឋមវ័យសម្រាប់ទារក និងកុមារវ័យក្មេងនៃរដ្ឋ Washington

---

សូមថ្លែងអំណរគុណដល់មាតាបិតា និងបណ្តាអ្នកជំនាញការដទៃៗទៀត ដែលបានចែករំលែកគំនិតយោបល់របស់ពួកគាត់ដល់យើង ដែលរួមមានឈ្មោះដូចតទៅ៖

**Rita Dickey, Linda Gil, Terri Larson, Kathy Lollar, Julie Martino, Kathie Moudy, Joni Strong, Diana Sandoval និង Debbie Yanak**។

សូមឧទ្ទិសស្នាដៃដល់រដ្ឋ Maryland និងរដ្ឋ Pennsylvania ដែលបានអនុញ្ញាតឲ្យយើងប្រើកូនសៀវភៅរបស់ពួកគេ ធ្វើជាគំរូក្នុងការចងក្រងសៀវភៅមគ្គុទេសក៍នៃរដ្ឋ Washington។







*DCYF មិនរើសអើង និងផ្តល់លទ្ធភាពទទួលបានកម្មវិធី និងសេវាកម្មរបស់ខ្លួនស្មើគ្នាដល់មនុស្សទាំងអស់ដោយមិនគិតពីជនជាតិ ពណ៌សម្បុរ ភេទ យេនឌ័រ សាសនា ជំនឿ ស្ថានភាពអាពាហ៍ពិពាហ៍ ដើមកំណើតជាតិសាសន៍ ទំនោរផ្លូវភេទ អាយុ ស្ថានភាពអតីតយុទ្ធជន ឬមានពិការភាពផ្លូវកាយ ពិការភាពវិញ្ញាណ ឬពិការភាពផ្លូវចិត្តឡើយ។*

*ប្រសិនបើអ្នកចង់បានច្បាប់ចម្លងដោយឥតគិតថ្លៃនៃការចេញផ្សាយនេះជាទម្រង់ ឬភាសាផ្សេងទៀត DCYF Constituent Relations (ទំនាក់ទំនងសំខាន់របស់ DCYF) តាមលេខ 1-800-723-4831 ឬផ្ញើអ៊ីមែលទៅ* ***communications@dcyf.wa.gov***។

DCYF PUBLICATION FS_0002 | DEL 11-005 CA (07-2023) Cambodian